# កិច្ចពិភាក្សាត្រីភាគី

## ស្តីពី

## ការលើកកំពស់កិច្ចគាំពារសង្គម និងការបង្កើនមុខរបរ និងការងារ

## រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## បទឧទ្ទេសនាម

# ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម

ដោយ **ឌី ចន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

ថ្ងៃទី ២៨-២៩ ខែមិនា ឆ្នាំ២០១២ — មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

(សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

**សូមគោរពគណអធិបតី**

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

**អង្គសិក្ខាសាលាទាំងមូល ជាទីគោរពមេត្រី**

១. ជាបឋម ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ខ្ញុំសូមសំដែងនូវការអរគុណចំពោះការអញ្ជើញឱ្យមកចូលរួមក្នុងអង្គពិធីក្នុងឱកាសនេះ។ ប្រធានបទនៃអង្គសិក្ខាសាលានាពេលលើកឡើង ពីការលើកកំពស់កិច្ចគាំពារសង្គម និងការបង្កើនមុខរបរ និងការងារ។ ដោយហេតុថា រាជរដ្ឋាភិបាលបានសម្រេច និងបានដាក់ចេញឱ្យអនុវត្ត នូវយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ហើយបានធ្វើការផ្សព្វផ្សាយជាផ្លូវការរួចហើយក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី កាលពីថ្ងៃ៥ ខែធ្នូ ឆ្នាំ ២០១១កន្លងមក បន្ទាប់ពីបានទទួលការសិក្សាពិគ្រោះយោបល់ពីគ្រប់ស្ថាប័នរដ្ឋ និងភាគីដៃគូពាក់ព័ន្ធអស់ រយៈជាង២ឆ្នាំ និងបានទទួលការអនុម័តដោយគណៈរដ្ឋមន្ត្រីកាល ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១។ អង្គសិក្ខាសាលាថ្ងៃនេះ គឺជាជំហានមួយក្នុងរៀបចំធ្វើសង្គតិភាពនៃគោលនយោបាយ ដើម្បីជំរុញការអនុវត្ត យុទ្ធសាស្ត្រនេះឱ្យរិតតែមានប្រសិទ្ធភាព និងប្រទាក់ក្រឡាគ្នាថែមទៀត។ បទឧទ្ទេសនាមរបស់ខ្ញុំនៅក្នុងសិក្ខាសាលានេះ គឺផ្តោតសារសំខាន់ទៅលើការងារត្រៀមអនុវត្ត យុទ្ធសាស្ត្រជាតិគាំពារសង្គមនេះ។

២.	តាមពិតទៅកម្មវិធីសុវត្ថិភាពសង្គម ដែលជាផ្នែកសំខាន់មួយនៃការគាំពារសង្គម មិនមែនការងារថ្មីសម្រាប់កម្ពុជាទេ។ រយៈពេលជាង ២០ឆ្នាំកន្លងមក កម្ពុជាបានអនុវត្តកម្មវិធី និងគម្រោងជាច្រើនមកហើយ ដើម្បីធ្វើសមារណហកម្មនិតិសម្បទា និងដើម្បីលើកកំពស់សន្តិសុខស្បៀង អាហារូបត្ថម្ភ ឆ្លើយតបទៅនឹងស្ថានភាពសង្គ្រោះបន្ទាន់ផង និងដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្រីក្រផង។ សកម្មភាពទាំងឡាយមានជាអាទិ :

- ការចែកចាយសម្ភារៈកសិកម្ម ស្បៀង ការផ្តល់អាហារតាមសាលារៀន កម្មវិធីស្បៀងពលកម្ម
- ការផ្តល់ប្រាក់ពលកម្ម អាហារូបករណ៍ចំពោះសិស្សកុមារក្រីក្រ
- កម្មវិធីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- មូលនិធិសមធមិសុខភាព និងគម្រោងធានារ៉ាប់រងសុខភាពនៅតាមសហគមន៍
- មូលនិធិរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងមន្ត្រីរាជការ
- ការផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាដើម

៣.	កម្មវិធីទាំងអស់នេះសុទ្ធតែទទួលជោគជ័យក្នុងការផ្តល់ជូនអ្នកទទួលផលក្នុងចំនួនច្រើន និងការបង្កើនលទ្ធភាពទទួលបាននូវសេវាកម្មស្បៀងអាហារ និងសន្តិសុខនៃការរកប្រាក់ចំណូល។ ប៉ុន្តែមកដល់ដំណាក់កាលនេះទៅហើយ តើយើងមានហេតុផលអ្វីដែលយើងចាំបាច់មានយុទ្ធសាស្ត្រនេះ នៅពេលដែលស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាលបានកំណត់ជាអាទិភាព និងក៏កំពុងអនុវត្តយុទ្ធសាស្ត្រតាមវិស័យរៀងៗខ្លួនយ៉ាងសកម្មទៅហើយនោះ? ខ្ញុំសូមអនុញ្ញាតិលើកឡើងហេតុផលតែពីរ មកបង្ហាញជូនអង្គពិធីដើម្បីជ្រាបជាជំនួយស្មារតី។

៤.	**ទី១ ប្រទេសកម្ពុជាបានឆ្លងច្រើនដំណាក់កាលនៃការអភិវឌ្ឍន៍ (សង្គ្រោះបន្ទាន់ ការស្តារនីតិសម្បទា និងការអភិវឌ្ឍន៍)** ហើយបានងើបផុតឡើងក្រោយពីបានជួបវិបត្តិជាច្រើនទស្សវត្សកន្លងមក និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាលើ១០% រយៈពេលបួនឆ្នាំជាប់ៗគ្នា មកដល់ឆ្នាំ២០០៧។ អត្រាភាពក្រីក្រ បានធ្លាក់ពី៤៧% នៅឆ្នាំ១៩៩៣-១៩៩៤ មកត្រឹមរង្វង់២៦%នៅឆ្នាំ២០១០។ កំណើនសេដ្ឋកិច្ចគិតជាផលិតសរុបក្នុងស្រុកមានការកើនឡើងទ្វេដង ក្នុងរយៈពេល១០ឆ្នាំ (១៩៩៤-២០០៤) និងកើនឡើង៣ដងក្នុងរយៈពេល១៥ឆ្នាំ (១៩៩៤-២០០៩)។ នៅឆ្នាំ២០២០ សេដ្ឋកិច្ចនៅកម្ពុជា អាចកើនឡើងទ្វេដងថែមទៀត ការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចមានការរីកចម្រើន ឈានទៅកាត់បន្ថយ អត្រាភាពក្រីក្របានមួយកម្រិតទៀត។ កម្ពុជាអាចនឹងងើបផុតចេញពីក្រុមប្រទេសក្រីក្រ ដែលកំពុងអភិវឌ្ឍន៍ទៅក្នុងចំណោម

ប្រទេសបានអភិវឌ្ឍន៍ មានប្រាក់ចំណូលមធ្យម និងអាចជាកូនខ្លាមួយក្នុងតំបន់ផងដែរ។ ស្ថានភាពនេះទាមទារឱ្យយើងលើកកម្ពស់ការអភិវឌ្ឍន៍មួយកំរិតថែមទៀត ទាំងផលិតភាព ប្រសិទ្ធភាព និងសមធម៌ស្របតាមទិសដៅនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ គឺដើម្បី កំណើន ការងារ ប្រសិទ្ធភាព និងសមធម៌។ កំណែទម្រង់រដ្ឋទាំងឡាយដែលបានដាក់ចេញជាបន្តបន្ទាប់ត្រូវតែបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។ ការគាំទ្រដល់ក្រុមជនក្រីក្រនិងជនងាយរងគ្រោះ គឺជាការចាំបាច់មិនអាចរំលងបានជាមួយ និងការបង្កើន ពង្រឹងមូលធនមនុស្សដែលយើងត្រូវប្រែក្លាយក្រុមជនក្រីក្រនិងជនងាយរងគ្រោះទៅជា កម្លាំងផលិត និងជា ធនធានមនុស្សចូលរួមចំណែកជាសកម្មដល់ការអភិវឌ្ឍន៍ជាតិយូរអង្វែង។

៥. **ទី២ គ្រួសារនៅកម្ពុជា នៅជួបប្រទះវិបត្តិ និងអាចប្រឈមនឹងភាពងាយរងគ្រោះដោយសារហេតុផលជាលក្ខណៈបុគ្គល និងវិបត្តិគលិយុគសេដ្ឋកិច្ច**។ ដោយសារប្រជាពលរដ្ឋកម្ពុជា ប្រកបការងារកសិកម្ម បម្រើដល់ការផ្គត់ផ្គង់គ្រួសារពឹងផ្អែកលើស្ថានភាពអំណោយផលពីធាតុអាកាសភាពរាំងស្ងួតនិងអសន្តិសុខស្បៀងគឺជាកង្វល់ធំធេង។ ជម្ងឺ និងការចំណាយច្រើនលើការថែរក្សាសុខភាព ក៏ជាប្រភពជំរុញឱ្យគ្រួសារពួកគាត់ឆាប់ធ្លាក់ចុះនៅក្នុងភាពក្រីក្រតោកយ៉ាក បញ្ឈប់កូនពីសាលារៀន ដោះដូរទ្រព្យធនតិចតួច ដើម្បីដោះស្រាយបញ្ហាទុរភិក្សនានា។ អត្រាកង្វះអាហារូបត្ថម្ភនៃកុមារនិងម្តាយ នឹងធ្វើឱ្យរាំងស្ទះដល់ការលូតលាស់របស់កុមារបាត់បង់ការរៀនសូត្រ និងបាត់បង់ឱកាសមួយជីវិត។ ស្ថានភាពក្រីក្រ និងភាពងាយរងគ្រោះនៃក្រុមគ្រួសារមួយចំនួន ក៏បានរងគ្រោះបន្ថែមដោយសារការឡើងថ្លៃស្បៀង និងវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដែលធ្វើឱ្យបាត់បង់ការងារធ្វើ ប្រាក់ចំណូល និងមិនទទួលបានសេវាចាំបាច់នានា ព្រមទាំងបានជំរុញពួកគាត់ឱ្យរិតតែធ្លាក់កាន់តែជ្រៅនៃបន្ទាត់ក្រីក្រ។

៦. ប្រឈមទៅនឹងស្ថានភាពងាយរងគ្រោះនៅកម្ពុជា និងដើម្បីបន្តអនុវត្តកំណែទម្រង់រដ្ឋនានាដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងជំរុញកំណើនសេដ្ឋកិច្ចខ្ពស់និងមានស្ថេរភាព កម្ពុជាត្រូវការពង្រីកវិសាលភាពគ្របដណ្តប់នៃការគាំពារសង្គម នឹងជួយដល់ការកាត់បន្ថយភាពក្រីក្រតោកយ៉ាក ជួយសម្រាលជនក្រីក្រក្នុងការឆ្លើយតបរាល់ហានិភ័យដែលអាចកើតឡើង ឈានទៅបង្កើនមូលធនមនុស្ស និងលើកកម្ពស់ផលិតភាព និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព។ **ក្នុងទិសដៅនេះ ការផ្សារភ្ជាប់កិច្ចគាំពារសង្គម និងការបង្កើនមុខរបរ និងការងារ គឺមានសារសំខាន់បំផុតសម្រាប់ធានាឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌។** (លើកយកឧទាហរណ៍ ដំណាំកៅស៊ូ និងតម្រូវការកម្មករនៅពេលយកផល — ចៀវជ័រ ក្នុងរយៈ៣ ទៅ៥ឆ្នាំខាងមុខ)។

៧. យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ជាយុទ្ធសាស្ត្រសម្របសម្រួល និងមិនមែនជាយុទ្ធសាស្ត្រតាមវិស័យ ដែលបានរៀបចំចងក្រងឡើងនៅក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងអនុវត្តដោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣។ ការគាំពារសង្គម គឺជាការវិនិយោគសម្រាប់ការអភិវឌ្ឍន៍ជាតិ ជួយដល់ការកាត់បន្ថយភាពក្រីក្រ បង្កើនតម្រូវការ និងការពង្រីកទីផ្សារ និងជួយដល់ការកសាងធនធានមនុស្សមានសុខភាពបរិបូណ៌ មានការសិក្សាចំណេះដឹងជំនាញខ្ពស់ និងមានកម្លាំងផលិតភាពគ្រប់គ្រាន់។

៨. ការគាំពារសង្គមគឺជាការឧបត្ថម្ភដែលផ្តល់ទៅដល់ប្រជាជន ដើម្បីដោះស្រាយទៅនឹងប្រភពចម្បងនានានៃភាពក្រីក្រ និងភាពងាយរងគ្រោះផង ព្រមទាំងដើម្បីបង្កើនការអភិវឌ្ឍន៍ធនធានមនុស្សផង។ ការគាំពារសង្គមរួមបញ្ចូលនូវការរៀបចំនិងប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទដើម្បីការពារបុគ្គល គ្រួសារ និងសហគមន៍ពីផលវិបាកផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ចនិងសង្គមដែលកើតឡើងពីហានិភ័យឬវិបត្តិ និងស្ថានភាពដែលធ្វើឱ្យកាន់តែក្រីក្រទាំងឡាយ ដើម្បីជួយពួកគេអាចចាកផុតពីភាពក្រីក្រ។ អន្តរាគមន៍នៃការគាំពារសង្គមក្នុងកម្រិតអប្បរមា រួមមានការធានារ៉ាប់រងសង្គម គោលនយោបាយទីផ្សារពលកម្ម បណ្តាញសុវត្ថិភាពសង្គម និងសេវាកម្មសុខមាលភាពសង្គម។ គឺដោយសារហេតុផលខាងលើនេះហើយ និងជាគោលនយោបាយចាំបាច់យូរអង្វែង ដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ ទើបរាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដែលក្នុងដំណាក់កាលនេះ កំណត់យកគោលដៅនៃក្រុមក្រីក្រ និងជនងាយរងគ្រោះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសិក្ខាសាលាទាំងមូលជាទីមេត្រី**

៩. ការអនុវត្តយុទ្ធសាស្ត្រនេះ នឹងទាមទារឱ្យពង្រីកបន្ថែមនូវអន្តរាគមន៍ដែលមានស្រាប់ ការរៀបចំស្ថាប័ន និងការបង្កើតឡើងនូវកម្មវិធីថ្មី ដើម្បីគ្រប់ដណ្តប់លើចន្លោះប្រហោង។ ជាថ្មីម្តងទៀតការអនុវត្តអន្តរាគមន៍គាំពារសង្គមជាភារកិច្ច និងជាការទទួលខុសត្រូវនៃក្រសួងជំនាញ និងស្ថាប័នអជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់។ យុទ្ធសាស្ត្រគាំពារសង្គម មានគោលបំណងក្នុងការបំពេញបន្ថែមនូវកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញក្នុងការសម្រេចឱ្យបាននូវគោលដៅតាមវិស័យជំនាញក្នុងវិធានការណ៍គាំពារសង្គម តាមរយៈការផ្តល់នូវក្របខណ្ឌនៃការអនុវត្តប្រកបដោយនិរន្តភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិ។

១០. វិញ្ញាសាថ្មីមួយទៀតដែលខ្ញុំសូមឱ្យមានការចូលរួមពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិ ទាំងរដ្ឋបាលមូលដ្ឋាន ព្រមទាំងដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ដើម្បីកំណត់រកឱ្យ

ឃើញជម្រើសកម្មវិធីជាអាទិភាព សម្រាប់ការរៀបចំបង្កើត និងពង្រីកវិសាលភាពកម្មវិធីគាំពារសង្គម ដើម្បីគ្របដណ្តប់លើគ្រប់ហានិភាព និងចន្លោះប្រហោងក្នុងការអនុវត្តនាពេលកន្លងមក។ វិញ្ញាសានៃការកំណត់ជម្រើសកម្មវិធី ត្រូវបង្ហាញពីភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ជាមួយនឹងយន្តការសម្របសម្រួលមួយច្បាស់លាស់ ជាមួយនិងយន្តការដែលមានស្រាប់។ អាស្រ័យហេតុនេះហើយ យើងត្រូវផ្តោតការយកចិត្តទុកដាក់ លើចំណុចមួយចំនួនដូចខាងក្រោម :

- ដោយសារយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាយុទ្ធសាស្ត្រសម្របសម្រួល ហើយមិនមែនជាយុទ្ធសាស្ត្រតាមវិស័យ ដូច្នេះ ផែនការសកម្មភាព ដែលមានលក្ខណៈស៊ីជម្រៅ ព្រមទាំងការពិភាក្សាសកម្មជាមួយក្រសួងជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ នឹងត្រូវបន្តធ្វើតទៅទៀតនៅពេលខាងមុខ ។
- ដើម្បីផ្លាស់ប្តូរពីសំណាញ់សុវត្ថិភាពសង្គម ឱ្យទៅជាប្រព័ន្ធគាំពារសង្គម ដែលមានលក្ខណៈស៊ីជម្រៅនិងទូលំទូលាយ កម្ពុជាត្រូវមានការប្រុងប្រយ័ត្នពីបញ្ហាភាពប្រេះឆាក្នុងសង្គម ដែលបណ្តាលមកពី ការផ្តោត ការយកចិត្តទុកដាក់តែទៅលើក្រុមពិសេសណាមួយក្នុងសង្គម។ ប្រការនេះ ទាមទារឱ្យមានការធានាសមភាពកំណើន និងការចូលរួមសម្រាប់មនុស្សគ្រប់ៗគ្នា។
- ដើម្បីជោគជ័យនៃការសម្រេចគោលបំណងយុទ្ធសាស្ត្រនេះ យើងត្រូវការចាំបាច់នូវការអនុវត្តកម្មវិធីមានលក្ខណៈចម្រុះ ដែលផ្តល់អត្ថប្រយោជន៍ និងគ្របដណ្តប់លើភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រ ដែលទើបនឹងកើតឡើង ក៏ដូចជាភាពអត់ឃ្លាន ព្រមទាំងជួយលើកកម្ពស់មូលធនមនុស្ស ។
- ការដោះស្រាយប្រភពសំខាន់ៗនៃភាពងាយរងគ្រោះនឹងជាសកម្មភាពអាទិភាព ក្នុងពេលជាមួយគ្នានេះគឺការកសាងមូលដ្ឋានសំណាញ់សុវត្ថិភាពសង្គមដែលមានប្រសិទ្ធភាពខ្ពស់ ។
- ការផ្សារភ្ជាប់ប្រភពសំខាន់នៃភាពងាយរងគ្រោះ ទៅនឹងកម្មវិធីនានា ទាមទារពង្រឹងយន្តការសម្របសម្រួល ការពង្រីក និងការធ្វើសុខដុមនីយកម្មលើអន្តរាគមន៍ដែលមានស្រាប់ ។
- ក្នុងការពង្រីកវិសាលភាពនៃអន្តរាគមន៍មួយចំនួន ប្រការសំខាន់គឺការធ្វើសុខដុមនីយកម្មលើ ដំណើរការនិងការធានាហិរញ្ញប្បទានឱ្យបានទៀងទាត់ ដើម្បីធានានិរន្តរភាពក្នុងរយៈពេលមធ្យម។ បន្ថែមលើនេះ វិសាលភាពនៃកម្មវិធីដែលមានស្រាប់នឹងត្រូវវាយតម្លៃជាថ្មីម្តងទៀត ហើយត្រូវកែតម្រូវជាមួយនឹងកម្រិតនៃភាពក្រីក្រ និងភាពងាយរងគ្រោះនៅថ្នាក់ខេត្ត និងថ្នាក់ ស្រុក ។

- ចន្លោះប្រហោងនៃការគាំពារសង្គមដែលមានស្រាប់ នឹងត្រូវដោះស្រាយដោយកម្មវិធីថ្មី ដែលនឹងជួយសម្រាលដល់បន្ទុកនៃភាពក្រីក្រភ័រ៉េ និងការបង្កើនមូលធនមនុស្ស។

**ឯកឧត្តម លោកជំទាវ អគ្គមេធិកានាំងមូលដ្ឋានីមេត្រី**

១១. យោងតាមបទពិសោធន៍នានាលើពិភពលោក យើងធ្វើការសង្កេតឃើញ និងអាចសន្និដ្ឋានបានថា នៅគ្រប់ប្រទេសជឿនលឿនទាំងអស់ ភាគច្រើនលើសលប់មានប្រព័ន្ធគាំពារសង្គមមានភាពរឹងមាំ និងគ្របដណ្តប់ទូលំទូលាយ។ យើងអាចនិយាយម្យ៉ាងទៀតថា នៅក្នុងប្រទេសណាដែលមានប្រព័ន្ធគាំពារសង្គមទាំងផ្លូវការ ក្រៅផ្លូវការ មានវិសាលភាពគ្របដណ្តប់គ្រប់សមាសភាពសង្គម ប្រទេសនោះទទួលបានស្ថេរភាពនយោបាយ មានកំណើនសេដ្ឋកិច្ចខ្ពស់ ហើយអាចប្រឈមគ្រប់ហានិភ័យដែលអាចកើតមានឡើងចំពោះមុខបាន។ នៅកម្ពុជា ទោះបីយើងនៅក្នុងចំណាត់ថ្នាក់ជាប្រទេសក្រីក្រក៏ពិតមែន ប៉ុន្តែដោយសាររាជរដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ អនុវត្តកំណែទម្រង់ស៊ីជំរៅគ្រប់វិស័យ ធ្វើបច្ចុប្បន្នកម្មគ្រប់កាលៈទេសៈ មានយុទ្ធសាស្ត្រត្រឹមត្រូវក្នុងការដោះស្រាយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ **ដោយមិនទុកឱ្យប្រជាជនខ្មែរណាម្នាក់ស្លាប់ដោយអត់បាយ និងមិនបានដឹង** ប្រទេសកម្ពុជាយើងទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់កន្លងមក។

១២. ប្រទេសកម្ពុជា នឹងវិវត្តន៍ទៅរកដំណាក់កាលថ្មីនៃសាកលភាវូបនីយកម្ម ដែលតម្រូវឱ្យយើងចាប់ផ្តើមពង្រឹងឧត្តមភាពរបស់យើងបន្ថែមទៀត ទាំងធនធានមនុស្ស ទាំងធនធានធម្មជាតិ ក្នុងការប្រកួតប្រជែង ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងមានសមធម៌។ អង្គសិក្ខាសាលាថ្ងៃនេះជាឱកាសដ៏ប្រពៃ ដែលយើងអាចធ្វើការពិភាក្សាលើតម្រូវការចាំបាច់សម្រាប់ ជំរុញការបង្កើនមុខរបរ និងការងារ សម្រាប់ប្រជនកម្ពុជា ឱ្យក្លាយទៅជាកម្រងសកម្មជាក់ស្តែង យកទៅអនុវត្តឱ្យមានប្រសិទ្ធភាព។ យើងត្រូវ ចេះកែឆ្នៃគ្រប់ហានិភ័យ ទៅជាកាលានុវត្តភាព សម្រាប់ជាប្រយោជន៍ដល់ប្រទេស និងប្រជាពលរដ្ឋកម្ពុជា គាំទ្រដល់ការអភិវឌ្ឍន៍យូរអង្វែង ដើម្បីសុខសន្តិភាព វឌ្ឍនភាព សុខុមាលភាព គ្រប់ៗគ្នា។

១៣. ជាទីបញ្ចប់ និងជាថ្មីម្តងទៀត យើងខ្ញុំសូមសំដែងនូវការអរគុណចំពោះការស្តាប់របស់ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ តំណាងគ្រប់ស្ថាប័ន និងជាសមាជិកនៃអង្គសិក្ខាសាលានេះ ដើម្បីឱ្យខ្ញុំមានឱកាសធ្វើការបង្ហាញជូននូវខ្លឹមសារពង្រាងយុទ្ធសាស្ត្រនេះ និងស្នើសុំការគាំទ្រ និងសហការជាបន្តទៀត នៅពេលអនុវត្តយុទ្ធសាស្ត្រនេះជាបន្តបន្ទាប់ ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងគោលដៅអភិវឌ្ឍន៍សហស្សវត្សនៅកម្ពុជា។ នៅក្នុងឱកាសចូលឆ្នាំខ្មែរថ្មី ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ខ្ញុំសូម

ប្រសិទ្ធពរជ័យសេរីមង្គលវិបុលសុខគ្រប់ប្រការចូរមានដល់គណអធិបតី ក្រុមគ្រួសារ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល សូមឱ្យមានសុខភាពល្អមាំមួន និងពុទ្ធពរទាំង ៤ប្រការ គឺអាយុ: វណ្ណ: សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**